# ជំនួយឧបត្ថម្ភដល់ការសិក្សាថ្នាក់បរិញ្ញាបត្រ

## ២០១៧-២០១៨

## ការិយាល័យប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក

# បទបញ្ញត្តិ

**ការប្រកាសជ្រើសរើសបេក្ខភាពថ្នាក់តំបន់ចាប់ពីថ្ងៃទី១៥ ខែកញ្ញា ដល់ថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៧**

## ១. គោលបំណង

ការប្រកាសជ្រើសរើសនេះសំរាប់តែនិស្សិតថ្នាក់បរិញ្ញាបត្រដែលបានចុះឈ្មោះចូលរៀនក្នុងកម្មវិធីបណ្ដុះបណ្ដាលជាភាសាបារាំងនៅតាមសាកលវិទ្យាល័យជាសមាជិករបស់ AUF ក្នុងតំបន់អាស៊ីអាគ្នេយ៍ (កម្ពុជា ឡាវ វៀតណាម)។ ជំនួយឧបត្ថម្ភការសិក្សានេះផ្ដល់ជូននិស្សិតដោយផ្ដោតទៅលើកត្តាសង្គម ក្នុងការជួយដល់និស្សិតក្រីក្រដែលជួបការលំបាកផ្នែកហិរញ្ញវត្ថុក្នុងការសិក្សា ។

បញ្ជីឈ្មោះការបណ្ដុះបណ្ដាលថ្នាក់បរិញ្ញាបត្រជាភាសាបារាំងអាចរកមើលបានតាមរយៈអាស័យដ្ឋាន៖
http://www.auf.org/bureau-asie-pacifique/actions-regionales/formations-francophones-chuyen-nganh-i-hc-phap-ng/

## ២. លក្ខណ្ឌសំរាប់ការដាក់បេក្ខភា

ជំនួយឧបត្ថម្ភការសិក្សាគឺជាជំនួយហិរញ្ញវត្ថុផ្ដោតទៅលើកត្តាសង្គមដោយផ្ដល់ជូនដល់និស្សិតសិក្សាក្នុងកម្មវិធីបណ្ដុះ បណ្ដាលជាភាសាបារាំងក្នុងប្រទេសផ្ទាល់របស់ខ្លួន។

ការប្រកាសជ្រើសរើសបេក្ខភាពសំរាប់ឆ្នាំសិក្សា ២០១៧-២០១៨ នេះផ្ដល់ជូនដល់តែនិស្សិតកម្ពុជា ឡាវ វៀតណាម រៀនថ្នាក់បរិញ្ញាបត្រជាភាសាបារាំងនៅក្រោមគំរោងសហការជាមួយ AUF តែប៉ុណ្ណោះ ។

ជំនួយឧបត្ថម្ភការសិក្សាប្រចាំឆ្នាំត្រូវអនុម័តយល់ព្រមដោយគណៈកម្មការជំនាញថ្នាក់តំបន់តាមរយៈសំណុំលិខិតរបស់បេក្ខជន ជាមួយនឹងទឹកប្រាក់ឧបត្ថម្ភមានពីរជំរើស ៖ ជំរើស A ចំនួន ៣០០ ដុល្លារ និង ជំរើស B ចំនួន ១៥០ ដុល្លារ ។

ដូច្នេះបេក្ខជនត្រូវបញ្ជាក់នៅក្នុងលិខិតបង្ហាញពីគោលបំណង (*la lettre de motivation*) របស់ខ្លួននូវជម្រើសណាមួយ និងមូលហេតុសមស្របបញ្ជាក់ការស្នើសុំនោះ (ឧទាហរណ៍៖ ថ្លៃចុះឈ្មោះចូលរៀន)។

ដើម្បីស្នើសុំប្រាក់ឧបត្ថម្ភការសិក្សា បេក្ខជនត្រូវ៖

- ចុះឈ្មោះចូលរៀនឆ្នាំសិក្សា ២០១៧-២០១៨ នៅក្នុងការបណ្ដុះបណ្ដាលជាភាសាបារាំងនៅក្នុងគ្រឹះស្ថានឧត្ដមសិក្សាជាសមាជិករបស់ AUF
- ផ្ដល់ជូនគ្រប់ឯកសារទាមទារ៖ ប្រវត្តិការសិក្សា (CV) ព្រឹត្តិប័ត្រពិន្ទុ សញ្ញាប័ត្រ ជាដើម
- ដាក់សំណុំលិខិតបេក្ខភាពបំពេញត្រឹមត្រូវនិងទាន់ពេលវេលាកំណត់។

## ៣. ការជ្រើសរើសបេក្ខភាព

**<u>ប្រុងប្រយ័ត្ន</u>**

**ឬពួកថា៖**

សូមនិស្សិតជាបេក្ខជនជ្រាបថា AUF មិនមែនជាគ្រឹះស្ថានសាធារណៈដែលមានបេសកកម្មជាកាតព្វកិច្ចក្នុងការបង្រៀននៅតាមគ្រឹះស្ថានឧត្ដមសិក្សានិងការស្រាវជ្រាវនោះទេ ។ ដូច្នេះហើយការផ្ដល់ជូនជំនួយឧបត្ថម្ភការសិក្សាមិនមែនជាការជ្រើសរើសនិស្សិត

អាហារូបករណ៍របស់ AUF ឬការជ្រើសរើសបុគ្គលិក ឬអ្នកនៅក្រោមបង្គាប់បញ្ជា ដែលត្រូវមានទំនាក់ទំនងរវាង AUF និងបេក្ខជនជ្រើសរើសនោះទេ ។ ទឹកប្រាក់ជំនួយឧបត្ថម្ភនេះមិនមែនជាប្រាក់ខែ ឬក៏ជាប្រាក់ឈ្នួលអ្វីនោះទេ ពីព្រោះវាមិនមែនទទួលបានមកពីការបំពេញការងារជាមួយ AUF នោះឡើយ។ ការសិក្សានិងការបណ្តុះបណ្តាលរបស់និស្សិតស្ថិតនៅក្រោមការកំណត់ដោយច្បាប់ជាធរមាននៃគ្រឹះស្ថានសិក្សានិមួយៗរបស់និស្សិតផ្ទាល់។ លើសពីនោះទៅទៀត AUF មិនមានអំណាចខាងផ្នែកវិន័យ និង/ឬក៏ អំណាចត្រួតពិនិត្យតាមដានទៅលើនិស្សិតដែលទទួលបានជំនួយឧបត្ថម្ភការសិក្សានោះផងដែរ ។
បេក្ខជននិមួយៗដែលស្នើសុំជំនួយឧបត្ថម្ភការសិក្សារបស់ AUF ត្រូវបានលើកទឹកចិត្តយ៉ាងពេញលេញ ក្នុងការស្វែងរកជំនួយឧបត្ថម្ភផ្សេងៗទៀត ដែលអនុញ្ញាតិឱ្យគេបានបំពេញបន្ថែមនូវតម្រូវការជាក់ស្តែងរបស់ខ្លួន ក្នុងអំឡុងពេលនៃការសិក្សា ជាពិសេសទៅទៀតនោះ គឺជំនួយឧបត្ថម្ភពីគ្រឹះស្ថានឧត្តមសិក្សារបស់និស្សិតផ្ទាល់តែម្តង ។

**<u>និតិវិធី៖</u>**

បេក្ខជនត្រូវបំពេញទំរង់បែបបទស្នើជំនួយឧបត្ថម្ភសិក្សាលើអាំងទែណែតបានតាមរយៈគេហទំព័រ (https://formulaires.auf.org/) តាមថេរវេលាដែលបានកំណត់ ។ បេក្ខជននិមួយៗអាចបំពេញសំណុំលិខិតស្នើសុំបានតែមួយគត់។

បន្ទាប់ពីការពិនិត្យលើភាពត្រឹមត្រូវនៃបេក្ខភាពរបស់និស្សិត សំណុំលិខិតរបស់បេក្ខជនត្រូវបានដាក់ជូនគណៈកម្មាការជំនាញថ្នាក់តំបន់អាស៊ីប៉ាស៊ីហ្វិករបស់ AUF ដើម្បីសំរេចជ្រើសរើស។ សំណុំលិខិតរបស់បេក្ខជនត្រូវធ្វើការជ្រើសរើសផ្អែកលើលក្ខខណ្ឌសង្គម និងត្រូវឆ្លងយោបល់របស់សាស្រ្តាចារ្យទទួលបន្ទុកការបណ្តុះបណ្តាលនៃគ្រឹះស្ថានសិក្សារបស់បេក្ខជន និង ស្របទៅតាមចំនួនថវិការនៃគម្រោងដែលមាន ។
លក្ខណៈវិនិច្ឆ័យសំខាន់ៗសំរាប់និតិវិធីក្នុងការជ្រើសរើសមានដូចជា ៖

- ស្ថានភាពផ្ទាល់ខ្លួន និង គ្រួសាររបស់បេក្ខជន
- គម្លាតឆ្ងាយរវាង លំនៅដ្ឋាន និង គ្រឹះស្ថានសិក្សា
- ក្នុងករណីដែលសំណុំលិខិតមានលក្ខណៈល្អប្រហាក់ប្រហែលគ្នា បេក្ខភាពនារី និង/ឬ អ្នកដែលមានលទ្ធផលសិក្សាល្អ នឹងត្រូវទទួលបានបុព្វសិទ្ធិ
- មតិយោបល់របស់អ្នកទទួលបន្ទុកផ្នែកបណ្តុះបណ្តាលតាមគ្រឹះស្ថានសិក្សា។

## ៤. របៀបផ្តល់ជំនួយឧបត្ថម្ភដល់ការសិក្សា

ជំនួយឧបត្ថម្ភការសិក្សាផ្តល់ជូនសំរាប់តែរយៈពេលមួយឆ្នាំសិក្សា។ បេក្ខជនត្រូវធ្វើការស្នើសុំបន្តជំនួយឧបត្ថម្ភការសិក្សានេះរៀងរាល់ឆ្នាំសិក្សា ។

## ៥. វិធីផ្តល់ជំនួយថវិការរបស់ AUF

ទឹកប្រាក់ឧបត្ថម្ភការសិក្សាផ្តល់ជូនជាពីរដំណាក់កាល សំរាប់និស្សិតរៀននៅក្នុងកម្មវិធីបណ្តុះបណ្តាលជាភាសាបារាំង (នៅរាល់ចុងបញ្ចប់នៃឆមាសនិមួយៗ)។ ជំនួយឧបត្ថម្ភការសិក្សាប្រចាំឆ្នាំត្រូវបានអនុម័តយល់ព្រមតាមរយៈសំណុំលិខិតរបស់បេក្ខជនជាមួយការស្នើសុំប្រាក់ឧបត្ថម្ភពីរជម្រើស ៖ ជំរើស A ចំនួន ៣០០ ដុល្លារ និង ជំរើស B ចំនួន ១៥០ ដុល្លារ ។
ក្នុងករណីដែលគ្រឹះស្ថានសិក្សាជូនដំណឹងដល់ AUF ពីការបញ្ឈប់មុនពេលកំនត់នូវការសិក្សារបស់បេក្ខជន ឬក៏និស្សិតមិនគោរពតាមលក្ខណ្ឌនៃការផ្តល់ជំនួយហិរញ្ញវត្ថុ នោះAUF អាចព្យួរ ឬលុបចោលការផ្តល់ប្រាក់ឧបត្ថម្ភបន្ទាប់ ។

## ៦. កាតព្វកិច្ចរបស់គ្រឹះស្ថានសិក្សារបស់បេក្ខជន

គ្រឹះស្ថានសិក្សារបស់និស្សិតដែលទទួលជំនួយឧបត្ថម្ភការសិក្សាសូមសន្យាថា ៖

- ឱ្យនិស្សិតគោរពនូវបទបញ្ញត្តិដែលបានចែងខាងលើនេះ
- ជូនដំណឹងយ៉ាងឆាប់រហ័សបំផុតដល់ AUF គ្រប់ការបញ្ឈប់មុនពេលកំនត់នូវការសិក្សារបស់និស្សិតដែលទទួលបានជំនួយឧបត្ថម្ភការសិក្សា
- ឱ្យនិស្សិតគោរពនូវច្បាប់ជាធរមាននៃព្រះរាជាអាណាចក្រកម្ពុជាឱ្យនិស្សិតគោរពនូវបទបញ្ញត្តិជាធរមានផ្សេងៗរបស់គ្រឹះស្ថានឧត្តមសិក្សា។

## ៧. ប្រតិទិន

- ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៧ ៖ ចាប់ផ្តើមការផ្សព្វផ្សាយការប្រកាសជ្រើសរើសបេក្ខភាព
- ថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៧ ៖ បិទការប្រកាសជ្រើសរើសបេក្ខភាព
- ខែវិច្ឆិកា ឆ្នាំ២០១៧ ៖ ប្រកាសលទ្ធផលនៃការជ្រើសរើសបេក្ខភាព (បញ្ជីឈ្មោះសំរេចចុងក្រោយ)

## ៨. ការរៀបចំសំណុំលិខិតបេក្ខភាព

សំណុំលិខិតបេក្ខភាពត្រូវតែបំពេញលើអ៊ីនទ័រណែតតាមរយៈអាស័យដ្ឋាន (https://formulaires.auf.org/) និងត្រូវគោរពថេរវេលាដែលបានកំណត់ ។

ដើម្បីឱ្យមានលក្ខណៈពេញលេញ និងត្រឹមត្រូវ សំណុំលិខិតបេក្ខភាពត្រូវភ្ជាប់មកជាមួយនូវឯកសារមួយចំនួនមានដូចតទៅ (ត្រូវភ្ជាប់ជាមួយទំរង់បែបបទនៃការស្នើរសុំ) ៖

១. ប្រវត្តិការសិក្សា (CV) ដែលបានធ្វើបច្ចុប្បន្នភាព ត្រូវសរសេរជាភាសាបារាំង ឬ ខ្មែរ រួមជាមួយរូបថតបញ្ជាក់អត្តសញ្ញាណមួយសន្លឹក

២. ព្រឹត្តិប័ត្រពិន្ទុនៃឆ្នាំសិក្សាកន្លងមក ជាភាសាខ្មែរ និង/ឬ បកប្រែជាភាសាបារាំង (សំរាប់បេក្ខជនរៀនចាប់ពីឆ្នាំទី២ឡើងទៅ)

៣. ច្បាប់ថតចម្លងព្រឹត្តិប័ត្រពិន្ទុនៃការប្រលងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ (សំរាប់បេក្ខជនកម្ពុជា និង ឡាវ រៀនឆ្នាំទី១)

៤. វិញ្ញាបនបត្របញ្ជាក់ពីស្ថានភាពក្រីក្ររបស់គ្រួសារ ចេញដោយអាជ្ញាធរមានសមត្ថកិច្ចសង្កាត់ ឬ ឃុំ ដែលគ្រួសាររបស់បេក្ខជនកំពុងស្នាក់នៅ

**គ្រប់ឯកសារដែលត្រូវភ្ជាប់ជាមួយសំណុំលិខិតបេក្ខភាពទាំងអស់ ត្រូវសរសេរជាភាសាបារាំង ឬ ខ្មែរ**
**អវត្តមានឯកសារណាមួយក្នុងចំណោមឯកសារខាងលើ បេក្ខជនត្រូវធ្លាក់ជាស្វ័យប្រវត្តិ**

ក្រោយពីឱ្យសុពលភាពលើសំណុំលិខិតបេក្ខភាពរួចហើយ បេក្ខជនមិនអាចបញ្ចូលបន្ថែម ឬដកចេញនូវឯកសារ ឬលិខិតស្នាម

ណាមួយបានឡើយ បើទោះបីជាការប្រកាសជ្រើសរើសបេក្ខភាពនៅមានសុពលភាពនៅឡើយក៏ដោយ។ រាល់សំណុំលិខិតបេក្ខភាពមិនអនុញ្ញាតិឱ្យផ្ញើតាមប្រអប់ប្រៃណីយ៍ ឬ ទូរសារឡើយ ។
បេក្ខជនម្នាក់ៗអាចធ្វើការស្នើសុំជំនួយឧបត្ថម្ភការសិក្សាតែមួយដងគត់ក្នុងមួយឆ្នាំសិក្សា ។

# ឧបសម្ព័ន្ធ ៖ ទំនាក់ទំនងសាកសួរព័ត៌មាននៅ AUF ប្រចាំនៅតំបន់អាស៊ីប៉ាស៊ីហ្វិកនិងនៅតាមការិយាល័យប្រចាំប្រទេសនិមួយៗ

### ការិយាល័យប្រចាំនៅតំបន់អាស៊ីប៉ាស៊ីហ្វិកនៅទីក្រុងហាណូយ

*លោកស្រី DINH Thi Hai Yen, អ្នកទទួលបន្ទុកគំពោង ទូរស័ព្ទ*
*អ៊ីម៉ែល : dinh.hai.yen@auf.org*
*ទូរស័ព្ទ : (+84) 24 38 24 73 82 (ext. 23)*

### ការិយាល័យប្រចាំនៅទីក្រុងហូជីមិញ

*លោក NGUYEN Tan Dai, ប្រធាន CNF*
*អ៊ីម៉ែល : nguyen.tan.dai@auf.org*
*ទូរស័ព្ទ : (+ 84) 28 38 27 95 50 (ext. 104)*

### ការិយាល័យប្រចាំនៅប្រទេសកម្ពុជា

*លោក IM Kravong,ប្រធានការិយាល័យប្រចាំនៅប្រទេសកម្ពុជា*
*អ៊ីម៉ែល : kravong.im@auf.org*
*ទូរស័ព្ទ : (+855) 23 883 135/136 (ext. 12)*

### ការិយាល័យប្រចាំនៅប្រទេសឡាវ

*លោកស្រី Julie El Moutaoukil Rousseau, ប្រធានការិយាល័យប្រចាំនៅប្រទេសឡាវ*
*អ៊ីម៉ែល : julie.el-moutaoukil-rousseau@auf.org*
*ទូរស័ព្ទ : (+ 856) 21 31 46 99*